ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ ៤៤១៣ អពដ

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥

## សេចក្តីជូនដំណឹង
## ស្តីពី
## នីតិវិធីក្នុងការបង់ពន្ធលើមធ្យោបាយសម្រាប់ឆ្នាំ២០១៥ ចំពោះយានយន្តដែលបានផ្លាស់ប្តូរផ្លាកលេខថ្មី ឬធ្វើបច្ចុប្បន្នភាពព័ត៌មានយានយន្ត

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់ម្ចាស់យានយន្តនិងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីសម្រួលដល់ការគ្រប់គ្រង និង ប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៥ និងឆ្នាំទៅមុខទៀត អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំថា ចំពោះយានយន្តដែលបានផ្លាស់ប្តូរផ្លាកលេខថ្មី ឬផ្លាស់ប្តូរទិន្នន័យដូចជា យថាប្រភេទយានយន្ត ឬលេខតួ ឬលេខម៉ាស៊ីន ឬកម្លាំង ឬឆ្នាំផលិត ឬទម្ងន់សរុប ឬចំនួនកៅអី ដែលនាំឱ្យមានការកែប្រែប្រាក់ពន្ធ ត្រូវបានអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយសម្រាប់ឆ្នាំ២០១៥ ប៉ុន្តែតម្រូវឱ្យ ម្ចាស់យានយន្តបំពេញទម្រង់ស្នើសុំធ្វើបច្ចុប្បន្នភាពយានយន្តមកសាខាពន្ធដារខេត្ត ខណ្ឌ ឬសាខាធនាគារទាំងពីរដោយភ្ជាប់មកជាមួយនូវ÷

- ពាក្យស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានយានយន្ត (អាចទាញយកនៅតាមគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh)
- ច្បាប់ថតចម្លងប័ណ្ណសម្គាល់យានយន្តចាស់ (ប្រសិនបើមាន)
- ច្បាប់ថតចម្លងប័ណ្ណសម្គាល់យានយន្តថ្មី ឬ វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តថ្មី
- ច្បាប់ថតចម្លងបង្កាន់ដៃបង់ពន្ធលើមធ្យោបាយឆ្នាំ២០១៤
- អត្តសញ្ញាណប័ណ្ណរបស់ម្ចាស់កម្មសិទ្ធិយានយន្តថ្មី

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមជឿជាក់ថា នីតិវិធីក្នុងការបង់ពន្ធលើមធ្យោបាយសម្រាប់ឆ្នាំ២០១៥ ចំពោះយានយន្តដែលបានផ្លាស់ប្តូរផ្លាកលេខថ្មី ឬបច្ចុប្បន្នភាពព័ត៌មានយានយន្ត និងជួយសម្រួលដល់ម្ចាស់យានយន្តទាំងអស់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន ។

អគ្គនាយកដ្ឋានពន្ធដារ

Collection by VCAT Professional Consultant